# សេចក្តីថ្លែងការណ៍រួម

*រាជធានីភ្នំពេញ ថ្ងៃទី០២ ខែឧសភា ឆ្នាំ២០២២*

ក្រុមអង្គការ សមាគមសារព័ត៌មាន អ្នកសារព័ត៌មាន និងអង្គការសមាគមមិនមែនរដ្ឋាភិបាល ដែលកំពុងធ្វើការងារ ដើម្បីលើកកម្ពស់សិទ្ធិទទួលព័ត៌មាន សេរីភាពសារព័ត៌មាន និងសេរីភាពបញ្ចេញមតិក្នុងប្រទេសកម្ពុជា ចូលរួមអបអរសាទរទិវាសេរីភាពសារព័ត៌មានពិភពលោកឆ្នាំ២០២២។ ជាមួយនឹងការសាទរនៅក្នុងទិវាសេរីភាពសារព័ត៌មាននៅឆ្នាំនេះដែលធ្វើឡើងក្រោមប្រធានបទ "សារព័ត៌មានក្នុងសម្ពាធប្រព័ន្ធឌីជីថល" យើងខ្ញុំទាំងអស់គ្នាដែលមានរាយនាមដូចខាងក្រោម ទទូចស្នើសុំដល់រាជរដ្ឋាភិបាលនិងដៃគូពាក់ព័ន្ធទាំងអស់ បន្តយកចិត្តទុកដាក់ពិនិត្យតាមដាន និងដោះស្រាយនូវសំណើដូចខាងក្រោមនេះ៖

1. សូមចាត់វិធានការឱ្យមានប្រសិទ្ធភាពដើម្បីបញ្ចប់និទណ្ឌភាពចំពោះរាល់បទឧក្រិដ្ឋទាំងឡាយប្រឆាំងនឹងអ្នកសារព័ត៌មាន ដោយនាំយកជនដៃដល់និងអ្នកដែលរួមប្រព្រឹត្តឃាតកម្ម ការវាយប្រហារ ការគម្រាមកំហែង ការបៀតបៀន រូបរាងកាយ និងការបៀតបៀនផ្លូវភេទជាដើម មកផ្តន្ទាទោសទៅតាមផ្លូវច្បាប់ ដើម្បីផ្តល់យុត្តិធម៌ដល់ជនរងគ្រោះ និងសាច់ញាតិ។
2. សំណូមពរក្រសួងព័ត៌មានសូមពិនិត្យនិងផ្តល់សុពលភាពនូវអាជ្ញាបណ្ណព័ត៌មានឡើងវិញដល់បណ្តាញសារព័ត៌មានមួយចំនួន ដែលក្រសួងបានដកក្នុងឆ្នាំ២០១៧ មកដល់បច្ចុប្បន្ន ដើម្បីឱ្យពួកគាត់អាចបន្តចូលរួមក្នុងសកម្មភាពផ្តល់ព័ត៌មានជូនដល់ប្រជាពលរដ្ឋបន្តទៀត។
3. សូមបន្តអនុវត្តឱ្យមានប្រសិទ្ធភាព នូវការលើកឡើងរបស់ប្រមុខដឹកនាំរាជរដ្ឋាភិបាល **សម្តេចអគ្គមហាសេនាបតី តេជោ ហ៊ុន សែន** ដោយបន្តយន្តការជួបគ្នាជាប្រចាំឆ្នាំជាមួយនឹងអ្នកសារព័ត៌មាន ការអនុវត្តឱ្យមានប្រសិទ្ធភាពនូវការចាត់ទុកអ្នកសារព័ត៌មានថាជាដៃគូមិនអាចខ្វះបាន ដើម្បីជំរុញឱ្យមាន គណនេយ្យភាពសង្គមនិងការលុបបំបាត់អំពើអសកម្មនិងអំពើពុករលួយ ក៏ដូចជាការធ្វើឱ្យប្រសើរឡើងនូវសិទ្ធិទទួលព័ត៌មាន។ បន្ថែមពីនេះ សូមបន្តពង្រឹងភាពជាដៃគូមិនអាចខ្វះបាន រវាងរាជរដ្ឋាភិបាលជាមួយនឹងអ្នកសារព័ត៌មានបន្ថែមទៀត តាមរយៈការឆ្លើយតបប្រកបដោយវិជ្ជមាន និងទាន់ពេលវេលា និងដោះស្រាយនូវរាល់បញ្ហាដែលប្រឈមដល់ការងាររបស់អ្នកសារព័ត៌មាន។ ពិសេសជាងនេះទៀត សូមពង្រីកកិច្ចសហការនិងធ្វើការរួមគ្នាដើម្បីលើក

កម្ពស់ការយល់ ដឹងជូនប្រជាពលរដ្ឋអំពីអក្ខរកម្មប្រព័ន្ធផ្សព្វផ្សាយ ព័ត៌មាន និងប្រព័ន្ធឌីជីថល។

4. សូមរាជរដ្ឋាភិបាល ពន្លឿននិងបញ្ចប់សេចក្តីព្រាងច្បាប់ពាក់ព័ន្ធដូចជាច្បាប់ស្តីពីសិទ្ធិទទួលព័ត៌មាន ដើម្បីស្វែងរកការអនុម័តច្បាប់ពីសភាជាតិកម្ពុជា និងពន្លឿនដំណើរ ការវិសោធនកម្មច្បាប់ស្តីពីរបបសារព័ត៌មាន ដើម្បីជំរុញការទទួលបានព័ត៌មានបន្ថែមទៀតសម្រាប់អ្នកសារព័ត៌មាន។ ជាមួយគ្នានេះ ស្នើសុំបើកឱ្យមានការប្រឹក្សាយោបល់ទូលំទូលាយ រួមទាំងការទទួលយកនូវធាតុចូលពីដៃគូពាក់ព័ន្ធ ទៅលើសេចក្តីព្រាងច្បាប់ដែលពាក់ព័ន្ធ ដូចជាសេចក្តីព្រាងច្បាប់ស្តីពីឧក្រិដ្ឋកម្មតាមប្រព័ន្ធបច្ចេកវិទ្យា សន្តិសុខឌីជីថល និងវិធានគតិយុត្តផ្សេងទៀតដែលអាចនឹងប៉ះពាល់ដល់សិទ្ធិទទួលព័ត៌មាន សេរីភាពសារព័ត៌មាន និងសេរីភាពបញ្ចេញមតិ។
5. ចូលរួមឱ្យបានកាន់តែសកម្ម ដើម្បីឈានទៅលុបបំបាត់រាល់ទម្រង់នៃការបៀតបៀនលើស្ត្រីអ្នកសារព័ត៌មាន ដូចជាការបៀតបៀនដោយប្រើពាក្យសម្តី ការប្រមាថ និងការបៀតបៀនលើរូបរាងកាយនិងផ្លូវភេទជាដើម។ សកម្មភាពនេះនឹងជួយជំរុញឱ្យមានការចូលរួមកាន់តែច្រើនឡើងនៃចំនួនស្ត្រីនៅក្នុងវិស័យសារព័ត៌មាន ដែលចាំបាច់ណាស់ដើម្បីឱ្យគ្រប់បញ្ហារបស់ស្ត្រីនៅក្នុងសង្គមកាន់តែទទួលបានការយកចិត្តទុកដាក់ដោះស្រាយ និងឆ្លើយតប។
6. ផ្តល់ការលើកទឹកចិត្តឱ្យមានភាពចម្រុះនៃប្រព័ន្ធផ្សព្វផ្សាយពីគ្រប់និន្នាការគណបក្សនយោបាយ ដើម្បីធានាពីការ ទទួលបានព័ត៌មានទូលំទូលាយនិងគ្រប់ជ្រុងជ្រោយពីគ្រប់គណបក្សនយោបាយដែលនឹងចូលរួមប្រកួតប្រជែងនៅ ក្នុងដំណើរការបោះឆ្នោតឃុំសង្កាត់ក្នុងឆ្នាំ២០២២នេះ និងការបោះឆ្នោតជាតិនៅឆ្នាំ២០២៣។
7. បញ្ចប់ការប្រើប្រាស់ច្បាប់ស្តីពីក្រមព្រហ្មទណ្ឌចោទប្រកាន់និងចាប់អ្នកសារព័ត៌មានដាក់ពន្ធនាគារ ហើយធ្វើ វិសោធនកម្មខ្លឹមសារទាំងឡាយណាដែលធ្វើឱ្យប៉ះពាល់ដល់សិទ្ធិទទួលព័ត៌មាន សេរីភាពសារព័ត៌មាន និងសេរីភាពបញ្ចេញមតិ។

ទិវាសេរីភាពសារព័ត៌មាននៅឆ្នាំ២០២២នេះ ត្រូវបានរៀបចំឡើងដោយក្រុមអង្គការសមាគមសារព័ត៌មាន អ្នកសារព័ត៌មាន និងអង្គការសមាគមមិនមែនរដ្ឋាភិបាលចំនួន២៦ស្ថាប័ន។ កម្មវិធីពិភាក្សាដេញដោលដោយមានអ្នកចូលរួម ប្រមាណ២០០នាក់ បានរៀបចំឡើងពេញមួយថ្ងៃ នៅថ្ងៃទី២ ខែឧសភា ឆ្នាំ២០២២ នៅសណ្ឋាគារហ៊ីម៉ាវ៉ារី ក្នុងរាជធានី ភ្នំពេញ។ ប្រធានបទដែលបានលើកយកមកពិភាក្សារួមមាន ផលប៉ះពាល់នៃអនុក្រឹត្យ NIG និងអនុក្រឹត្យ PID លើសេរីភាពអ្នកសារព័ត៌មាននិងប្រព័ន្ធផ្សព្វផ្សាយ សិទ្ធិទទួលបានព័ត៌មាននិងការរាយ

ការណ៍អំពីការបោះឆ្នោត និងក្រមសីលធម៌របស់អ្នកសារព័ត៌មាននិងការជឿទុកចិត្តជាសាធារណៈ។ យើងមានសេចក្ដីសោមនស្សរីករាយដែលកម្មវិធីនេះនឹងមានការចូលរួមពីសំណាក់អ្នកដែលធ្វើការនៅក្នុងស្ថាប័ននិងមជ្ឈដ្ឋានការងារផ្សេងៗគ្នា ដោយរាប់ទាំងអ្នកសារព័ត៌មានពលរដ្ឋអ្នកសារព័ត៌មាន អ្នកការពារសិទ្ធិមនុស្ស តំណាងអង្គការសមាគមមិនមែនរដ្ឋាភិបាល អ្នកច្បាប់ តំណាងភ្នាក់ងារអង្គការសហប្រជាតិជាតិ មន្ត្រីមកពីស្ថាប័នរដ្ឋាភិបាល សមាជិកសភា និងតំណាងមកពីគណបក្សនយោបាយ។ល។ សាធារណជនទូទៅក៏ត្រូវបានលើកទឹកចិត្តឱ្យចូលរួមផងដែរ តាមរយៈការឆ្លើយសំណួរទាក់ទងនឹងសេរីភាព ដើម្បី ទទួលបានរង្វាន់ និងការតាមដានការផ្សាយផ្ទាល់ពីការប្រព្រឹត្តទៅនៃកម្មវិធីដែលបានផ្សាយផ្ទាល់តាមបណ្ដាញសង្គម។

**សម្រាប់ព័ត៌មានបន្ថែមសូមទាក់ទង៖**

លោកស្រី ឆន សុគន្ធា នាយកផ្នែកអភិវឌ្ឍប្រព័ន្ធផ្សព្វផ្សាយនៃមជ្ឈមណ្ឌលកម្ពុជាដើម្បីប្រព័ន្ធផ្សព្វផ្សាយឯករាជ្យ

093 831 990, csokunthea@ccimcambodia.org

លោក ណុប វី នាយកប្រតិបត្តិសមាគមសម្ព័ន្ធអ្នកសារព័ត៌មានកម្ពុជា (ខេមបូចា)

012 519 261; ed@camboja.net

1. អង្គការ សមាគមមិនមែនរដ្ឋាភិបាលដែលបានចូលរួមគាំទ្រសេចក្ដីថ្លែងការណ៍
2. សមាគមសម្ព័ន្ធអ្នកសារព័ត៌មានកម្ពុជា (CamboJA)
3. មជ្ឈមណ្ឌលកម្ពុជាដើម្បីប្រព័ន្ធផ្សព្វផ្សាយឯករាជ្យ (CCIM)
4. មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា (CCHR)
5. គណៈកម្មាធិការដើម្បីការបោះឆ្នោតដោយសេរី និងយុត្តិធម៌នៅកម្ពុជា (COMFREL)
6. មជ្ឈមណ្ឌលសម្ព័ន្ធភាពការងារ និងសិទ្ធិមនុស្ស (CENTRAL)
7. បណ្ដាញយុវជនកម្ពុជា (CYN)
8. អង្គការសមាគមធាងត្នោត (STT)
9. កម្មវិធីអភិវឌ្ឍន៍ធនធានយុវជន (YRDP)
10. អង្គការអាក់សិនអេតកម្ពុជា (AAC)
11. អង្គការអភិវឌ្ឍន៍សំលេងសហគមន៍ (BCV)
12. មណ្ឌលព័ត៌មាន ស្ត្រីកម្ពុជា (WMC)
13. សមាគមការពារសិទ្ធិមនុស្សនិងអភិវឌ្ឍន៍នៅកម្ពុជា (ADHOC)

14. អង្គការក្រុមការងារដើម្បីដោះស្រាយទំនាស់ (ACT)
15. វិទ្យាស្ថាន តស៊ូមតិ និងគោលនយោបាយ (API)
16. អង្គការថែរក្សាភាសាជនជាតិដើមភាគតិច (CIPL)
17. សមាគមប្រជាធិបតេយ្យឯករាជ្យនៃសេដ្ឋកិច្ចប្រព័ន្ធ (IDEA)
18. សមាគមយុវជនជនជាតិដើមភាគតិចកម្ពុជា (CIYA)
19. អង្គការតម្លាភាពកម្ពុជា (TIC)
20. គណៈកម្មាធិការសហប្រតិបត្តិការដើម្បីកម្ពុជា (CCC)
21. អង្គការសម្ព័ន្ធភាពដៃគូដើម្បីការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ (CPDD)
22. អង្គការមជ្ឈមណ្ឌលអប់រំច្បាប់សម្រាប់សហគមន៍ (CLEC)
23. សហព័ន្ធអ្នកសារព័ត៌មានអន្តរជាតិ (IFJ)